**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិ**

**គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

លេខ : ០៧០៥៦ ជនស/គ.អ.ឆ.ក.

ថ្ងៃអង្គារ ៥កើត ខែកក្ដិក ឆ្នាំរកា នព្វស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ ២០១៨

**ជម្រាបជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ**

**កម្មវត្ថុ:** សេចក្តីណែនាំ និងវិធានការស្តីពីការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូ សម្រាប់រាល់សំណង់អគារលំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម សណ្ឋាគារ ភោជនីយដ្ឋាន និងរោងចក្រ ដែលមានស្រាប់ និង/ឬគម្រោងសាងសង់ថ្មី នៅខេត្តព្រះសីហនុ

**យោង:**
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ ៣៣៩៦ ដនស/គអឆក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីសេចក្តីណែនាំបន្ថែមស្តីពីការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធបណ្តាញលូ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ជ្រាបថា ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ផាសុកភាព សោភ័ណភាព គុណភាពទឹកសមុទ្រ ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងឆ្នេរខ្សាច់កម្សាន្ត ឱ្យស្របតាមកិត្តិនាមជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនៅខេត្តព្រះសីហនុ រាល់សំណង់អគារលំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម សណ្ឋាគារ ភោជនីយដ្ឋាន និងរោងចក្រដែលមានស្រាប់ និង/ឬគម្រោងសាងសង់ថ្មី ត្រូវរៀបចំឱ្យមានអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូ ក្នុងទីតាំងដីឡូត៍រៀងៗខ្លួនជាមុន ស្របតាមមុខងារប្រើប្រាស់អគារ និងបទដ្ឋានបច្ចេកទេសសំណង់ និងបរិស្ថានល្អ រួចរៀបចំប្រព័ន្ធលូតភ្ជាប់ទឹកកខ្វក់ដែលចម្រោះរួចនេះចូលទៅប្រព័ន្ធលូសាធារណៈរបស់ខេត្ត ដែលហូរតភ្ជាប់ទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់របស់ខេត្តព្រះសីហនុ។

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ក្នុងករណីសំណង់ដែលមិនបានអនុវត្តតាមសេចក្តីណែនាំនេះ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ត្រូវចាត់វិធានការផ្អាកការសាងសង់ ឬផ្អាកការធ្វើអាជីវកម្មជាបណ្តោះអាសន្ន រហូតដល់មានការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូសមស្របតាមការណែនាំខាងលើជាមុន នៃសំណង់នីមួយៗរួច ទើបអនុញ្ញាតឱ្យបន្តការសាងសង់ ឬការធ្វើអាជីវកម្មឡើងវិញ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ទទួលនូវការរាប់អានពីខ្ញុំ៕

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

**ជា សុផារ៉ា**

**__ចម្លងជូន÷__**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ
- ឯកសារ កាលប្បវត្តិ